**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបោះជំរំកាយឬទ្ធិនៅកោះស្លា**
**ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៨**
*តួនាទីអ្នកទទួលខុសត្រូវជាន់ខ្ពស់*

អត្ថបទទី១៖ អស ៧,១០-១៤.៨,១០
អត្ថបទទី២៖ ហប ១០,៤-១០
ដំណឹងល្អ៖ លម ១,២៦-៣៨

បងប្អូនជាទីស្រឡាញ់!

សម្រាប់យើងជាមេក្រុមកាយឬទ្ធិ យើងជាអ្នកដែលទទួលខុសត្រូវជាន់ខ្ពស់ ពេលយើងមើលព្រះនាងម៉ារី យើងមានចំនុចបួនដើម្បីណែនាំឲ្យយើងគិត ខ្ញុំជាមេក្រុមកាយឬទ្ធិ ខ្ញុំធ្វើដូចម្តេចដើម្បីទទួលខុសត្រូវជាន់ខ្ពស់តាមរបៀបព្រះនាងម៉ារី?

ទីមួយ ឲ្យយើងឯកភាពជានិច្ច

ទីពីរ ឲ្យយើងបម្រើជានិច្ច

ទីបី ឲ្យយើងពោរពេញដោយអំណរសប្បាយជានិច្ច

ទីបួន ឲ្យយើងតស៊ូជានិច្ច។

ដើម្បីទទួលខុសត្រូវជាន់ខ្ពស់ជាមេក្រុមកាយឬទ្ធិ ដោយសម្លឹងមើលព្រះនាងម៉ារីដែលជាម្តាយរបស់យើង។ ប៉ុន្មានថ្ងៃមុនយើងគោរពព្រះយេស៊ូសោយទិវង្គត់ នៅក្បែរឈើឆ្កាងនៅសល់តែព្រះនាងម៉ារី និងសាវ័កជាទីស្រឡាញ់របស់ព្រះយេស៊ូ។ នៅពេលនោះព្រះយេស៊ូបានប្រទានព្រះនាងម៉ារីឲ្យសាវ័កជាទីស្រឡាញ់របស់ព្រះអង្គ ណែនាំឲ្យយើងទទួលព្រះនាងម៉ារីជាម្តាយរបស់យើងទាំងអស់គ្នា។ ម្តាយជាគំរូ ម្តាយជាអ្នកដែលបានណែនាំឲ្យយើងមើលឃើញពិភពលោកនេះ ម្តាយបានណែនាំឲ្យយើងចេះនិយាយ ចេះដើរ ចេះទទួលខុសត្រូវ។ ដូច្នេះយើងមើលម្តាយរបស់យើងគឺព្រះនាងម៉ារី៖

**ឯកភាពជានិច្ច** ព្រះនាងម៉ារីពេលគាត់បានទទួលដំណឹងពីទេវទូតកាព្រីអែល គាត់នៅក្មេងគាត់មិនសូវយល់ ប៉ុន្តែព្រះនាងម៉ារីបានឯកភាពជាមួយព្រះជាម្ចាស់ បានឯកភាពទទួលកាដូរមួយយ៉ាងពិសេសពីព្រះជាម្ចាស់។ ដូច្នេះសម្រាប់យើងដែលជាមេក្រុមកាយឬទ្ធិ ឲ្យយើងរស់នៅស្របតាមធម្មវិន័យរបស់ព្រះយេស៊ូ រស់នៅស្របតាមវិន័យនិងច្បាប់នៃក្រុមកាយឬទ្ធិ។ អ្វីដែលក្រុមការិយាល័យយុវជន ជំទង់ និងកុមារ ភូមិភាគភ្នំពេញ ចាត់ឲ្យយើងធ្វើយើងត្រូវតែឯកភាពជានិច្ច។ ក្រោយមកយើងមានមេតាមតំបន់ ដែលជួយសម្រុះសម្រួលតាមតំបន់ ដូច្នេះយើងត្រូវការធ្វើអ្វីដែលគាត់ណែនាំយើង។ ក្រោយមកយើងមានមេក្រុមកាយឬទ្ធិ ដែលណែនាំកូនក្មេង។ ហេតុនេះហើយ ឲ្យយើងចេះសម្រុះសម្រួលដោយឯកភាព ដោយគោរពវិន័យ និងស្តាប់អ្វីដែលយើងបានទទួលជាការអប់រំផ្សេងៗ។

**បម្រើជានិច្ច** ព្រះនាងម៉ារីបានឆ្លើយទៅទេវទូតកាព្រីអ៊ែលថា នាងខ្ញុំជាអ្នកបម្រើរបស់ព្រះជាអម្ចាស់។ សម្រាប់យើងដែលជាមេក្រុមកាយឬទ្ធិ ឲ្យយើងបម្រើជានិច្ច មិនចាំបាច់មានគេប្រើយើងទេ យើងត្រូវការបើកភ្នែកជានិច្ចដើម្បីឃើញសេចក្ដីត្រូវការ។ នៅក្នុងមង្គលការកាណា ព្រះនាងម៉ារីថា សូមយកចិត្តទុកដាក់អ្វីដែលលោកប្រាប់ឲ្យធ្វើអ្វីចូរធ្វើតាមទៅ។ ព្រះនាងម៉ារីយកចិត្តទុកដាក់ដោយមានចិត្តបម្រើជានិច្ច យើងមិនត្រូវការចាំគេប្រើយើង តែនៅក្នុងធម្មជាតិរបស់យើង យើងជួយ យើងបម្រើ ឲ្យយើងមានចិត្តបម្រើជានិច្ច។ យើងមិនធ្វើដោយសារយើងត្រូវការសងគុណ យើងមិនធ្វើដោយសារយើងចង់បានរង្វាន់ សម្រាប់យើងជាគ្រីស្ដបរិស័ទយើងជាអ្នកបម្រើជានិច្ច។ យើងធ្វើដោយដឹងថា យើងនឹងទទួលរង្វាន់យ៉ាងពិសេសបំផុតគឺជីវិតជាមួយព្រះជាម្ចាស់ យើងដឹងថាព្រះជាម្ចាស់មើលយើង និងព្រះជាម្ចាស់សប្បាយចិត្តជាមួយយើង ហើយព្រះអង្គណែនាំឲ្យយើងមានសេចក្ដីសុខរហូតដល់យើងបានជួបជាមួយព្រះជាម្ចាស់ផ្ទាល់។

**ពោរពេញដោយអំណរសប្បាយជានិច្ច** នៅព្រះនាងម៉ារីទទួលដំណឹងនេះហើយ ព្រះនាងម៉ារីប្រញាប់ប្រញាល់ទៅជួបយាងអេលីសាប៉ែត ដោយបានធ្វើដំណើរអស់រយៈពេលប្រាំពីរឬប្រាំបីថ្ងៃ។ ពេលគាត់ទៅដល់ភ្លាម ទោះបីក្ដៅយ៉ាងណាក៏ដោយគាត់បានចាប់ផ្ដើមច្រៀងកោតសរសើរព្រះជាម្ចាស់ និងកូនដែលនៅក្នុងផ្ទៃពោះអ្នកទាំងពីរបានបំរះឡើងដោយអំណរសប្បាយ។ សម្រាប់យើងដែលជាមេក្រុមកាយឬទ្ធិ ឲ្យយើងយកចិត្តទុកដាក់ថែរក្សាអំណរសប្បាយ កាលណាមានអំណរសប្បាយកូនក្មេងគេមកជានិច្ច។ កម្មវិធីកាយឬទ្ធិជាកម្មវិធីយើងបម្រើកូនក្មេង ដើម្បីលេងល្បែងជាមួយគ្នា ទទួលមេរៀនខ្លះៗអំពីធម្មជាតិ អំពីជីវិត អំពីទំនាក់ទំនង ដើម្បីអធិដ្ឋានខ្លះ ដើម្បីមានសកម្មភាពមួយចំនួនដែលណែនាំឲ្យគេមានអំណរសប្បាយ។ យើងត្រូវការថែរក្សាអំណរសប្បាយជានិច្ច ដើម្បីឲ្យកម្មវិធីកាយឬទ្ធិយើងរីកចម្រើនថែមទៀតនៅគ្រប់ទីកន្លែង។

**តស៊ូជានិច្ច** ព្រះនាងម៉ារីបានតស៊ូឆ្លងទន្លេនៅក្រោលគោ ក្រោយមកបានគេចខ្លួនទាំងសរសៃរខ្ចីទៅប្រទេសអេហ្ស៊ីប។ ជីវិតនៅណាសារ៉ែតតស៊ូ បាត់ព្រះយេស៊ូបីថ្ងៃដើររកកូននៅទីក្រុងយេរ៉ូសាឡឹមបានតស៊ូណាស់។ នៅពេលព្រះយេស៊ូមានអាយុ១២ឆ្នាំ ព្រះយេស៊ូបាននិយាយទៅព្រះនាងម៉ារីថា ដើររកខ្ញុំធ្វើអ្វីខ្ញុំនៅជាមួយព្រះបិតារបស់ខ្ញុំ ធ្វើឲ្យព្រះនាងម៉ារីភ្ញាក់មូលហេតុអ្វីកូនខ្ញុំនិយាយដូចនេះដាក់ខ្ញុំដែលជាម្ដាយ ព្រះនាងម៉ារីបានតស៊ូ។ នៅពេក្រុមសាវ័កដែលទូលព្រះយេស៊ូថា ម្ដាយរបស់លោកកំពុងរកលោក ព្រះយេស៊ូឆ្លើយថាអ្នកណាជាម្ដាយរបស់ខ្ញុំ? នៅពេលម្ដាយលឺដូចនេះម្ដាយឈឺចាប់ណាស់។ តស៊ូដល់កំពូលនៅថ្ងៃដែលព្រះយេស៊ូរងទុក្ខលំបាក ព្រះនាងម៉ារីបានឃើញគេចាប់កូនរបស់ខ្លួន វាយធ្វើទារុណកម្ម គេមើលងាយ និងគេសម្លាប់កូនគាត់ដោយឆ្កាងដូចឃាតករ។ នៅក្បែរឈើឆ្កាង

មានតែម្ដាយដែលកំពុងមើលកូនកំពុងស្លាប់។ សម្រាប់យើងដែលជាមេក្រុមកាយឬទ្ធិ យើងត្រូវការតស៊ូជានិច្ចដើម្បីបម្រើកូនក្មេង តស៊ូជានិច្ចដើម្បីគោរពពេលវេលា តស៊ូជានិច្ចដើម្បីរៀបចំមេរៀនយ៉ាងច្បាស់លាស់។ តស៊ូដើម្បីទៅជាមេក្រុមកាយឬទ្ធិ ពោរពេញដោយសេចក្ដីស្រឡាញ់ ពោរពេញដោយចិត្តបម្រើ និងពោរពេញដោយអំណរសប្បាយសម្រាប់កូនក្មេង។ ការតស៊ូត្រូវការមានផ្លែ ដូចព្រះនាងម៉ារីគាត់បានតស៊ូ ហើយបានឃើញព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ដើម្បីណែនាំឲ្យពិភពលោកទទួលសេចក្ដីសុខ និងទទួលសេចក្ដីសង្ឃឹម។ ដូច្នេះការតស៊ូរបស់យើង នឹងមានផ្លែអស្ចារ្យដើម្បីណែនាំឲ្យកូនម្នាក់ៗរីកចម្រើនផ្ទាល់ខ្លួន ឲ្យគេចេះជួយអ្នកដទៃ ចេះស្រឡាញ់បងប្អូនទាំងអស់ មានសីលធម៌ល្អ ចេះស្រឡាញ់វប្បធម៌និងប្រទេសរបស់ខ្លួន...។ នៅថ្ងៃអនាគត នៅពេលយើងឃើញកូនកាយឬទ្ធិរបស់យើងក្លាយជាមនុស្សល្អនៅក្នុងសង្គម មានន័យថាការតស៊ូរបស់យើងបានណែនាំឲ្យកូនក្មេងមួយចំនួនក្លាយជាពលរដ្ឋដ៏ល្អប្រសើរនៅក្នុងសង្គម។

សូមចាំ ទទួលខុសត្រូវជាន់ខ្ពស់ មើលម្ដាយរបស់យើងគឺព្រះនាងម៉ារី ដោយណែនាំឲ្យយើងឯកភាពជានិច្ច បម្រើជានិច្ច ពោរពេញដោយអំណរសប្បាយជានិច្ច និងតស៊ូជានិច្ច។ អាម៉ែន៕